# កិច្ចការ ២០:១៧-២១

The following is an abridged translation of a sermon by John Piper.  If you wish to read the original English, go to

http://www.desiringgod.org/sermons/serving-the-lord-with-humility-tears-and-trials

កណ្ឌគម្ពីរកិច្ចការគឺជាការរៀបរាប់យ៉ាងលឿនពីរឿងរីករាយនៃដំណឹងល្អចេញ ទូទាំងចក្រភពរ៉ូម៉ាំង នៅក្នុង រយៈពេល៣០ឆ្នាំដំបូង បន្ទាប់ពីព្រះយេស៊ូវរស់ពីសុគតឡើងវិញ។ ប៉ុន្តែយូរៗម្តង លោកលូកា រៀបរាប់រឿង យ៉ាងយឺតៗដើម្បីអោយយើងស្តាប់សេចក្តីអធិប្បាយម្តង។ ដូច្នេះ គាត់ជំរុញទឹកចិត្តយើងដោយរៀបរាប់ពីដំណឹងល្អចាប់ផ្តើមពីយេរូសាឡិមទៅដល់ស្រុកយូដា ទៅដល់ស្រុកសាម៉ារី និងទៅដល់ចក្រភពរ៉ូមទាំងមូល។ ប៉ុន្តែគាត់ក៏ឈប់ ដើម្បីបង្រៀនយើងពី  ប្រភេទគោលលទ្ធិ  ការអធិប្បាយ ភាពជាអ្នកដឹកនាំដែលគាំទ្រការរីកចម្រើនដ៏អស្ចារ្យនៃនគរព្រះផងដែរ។

## ដំណើរបេសកកម្មលើកទីបីរបស់សាវកប៉ុល

នៅក្នុងកិច្ចការ ១៨:២៣ សាវកប៉ុលចាប់ផ្តើមចេញដំណើរពីអាន់ទីយ៉ូកសំរាប់ដំណើរបេសកកម្មលើកទីបីនិងចុងក្រោយរបស់គាត់។ គាត់ធ្វើដំណើរតាមស្រុកកាឡាទីនិងស្រុកព្រីគា (សព្វថ្ងៃជាប្រទេសតួគី) ដើម្បីពង្រឹងពួកសិស្ស ដែលគាត់បានបង្កើតនៅក្នុងដំណើរបេសកកម្មលើកទីមួយរបស់គាត់។

នៅក្នុងកិច្ចការ ១៩:១ គាត់មកដល់អេភេសូរ។ ខ.៨ និយាយថា គាត់បានចំណាយពេលបីខែក្នុងការសួរនាំអំពីនគររបស់ព្រះជាមួយសហគមន៍សាសន៍យូដា។ ប៉ុន្តែ ដោយសារការទាស់ប្រឆាំងយ៉ាងខ្លាំង នោះសាវកប៉ុលបានចាកចេញពីសាលាប្រជុំ ហើយបានអធិប្បាយអស់រយៈពេលពីរឆ្នាំនៅក្នុងសាលាបង្រៀនទីរ៉ានុស។ នៅក្នុងកំឡុងពេលពីរឆ្នាំនេះ  មានការអស្ចារ្យផ្សេងៗបានកើតឡើង។

ព្រះបានធ្វើការអស្ចារ្យដូចជាប្រោសមនុស្សអោយជា និងដេញអារក្សតាមរយៈសាវកប៉ុល។ មនុស្សត្រូវបានសង្គ្រោះចេញពីគ្រូមន្តអាគម ហើយបានដុតក្បួនតម្រា ដែលមានតំលៃ៥០០០០ដួង  ចោល។ ភាពជោគជ័យរបស់សាវកប៉ុលនៅក្នុងការផ្សាយដំណឹងល្អមានភាពអស្ចារ្យ រហូតដល់ជាងប្រាក់ ដែលធ្វើអាស្រមព្រះឌីអានពីប្រាក់ បានភ័យខ្លាចអំពីមុខរបរពួកគេ និងព្រះវិហារព្រះឌីអានអាចត្រូវគេបំផ្លិចបំផ្លាញ។ ដូច្នេះ ពួកគេបានបង្កអោយមានភាពវឹកវរឡើង។ បន្ទាប់មក សាវកប៉ុលចាកចេញពីទីក្រុង បន្ទាប់ពីគាត់បានប្រកាសនិងបង្រៀនព្រះបន្ទូលនៅទីនោះអស់រយៈពេលជាងពីរឆ្នាំ។ (គាត់រាប់វាថាបីឆ្នាំនៅក្នុងកិច្ចការ ២០:៣១)។

គាត់ធ្វើដំណើរបន្តតាមស្រុកម៉ាសេដូន ហើយទៅដល់ក្រិក ប្រហែលចំណាយពេលបីខែក្នុងរដូវរងានៅក្នុងក្រុងកូរិនថូស (២០:៣)។ បន្ទាប់មក គាត់ត្រឡប់មកវិញតាមស្រុកម៉ាសេដូននៅក្នុងនិទាឃរដូវ ឆ្លងទៅ ត្រូ

អាស ជាកន្លែងដែលគាត់អធិប្បាយពេញមួយយប់ ហើយអ៊ើទីកុសបានគេងលក់ រួចបានធ្លាក់ចុះពីបង្អួច (២០:៩)។ គាត់ធ្វើដំណើរតាមសមុទ្រទៅភាគខាងត្បូង ហើយឆ្លងកាត់អេភេសូរតាមទូក ពីព្រោះគាត់ប្រញាប់ទៅឯយេរូសាឡិមនៅថ្ងៃបុណ្យទី៥០ (២០:១៦)។

## ការវិលត្រឡប់មកយេរូសាឡិម ឈប់នៅក្រុងមីលេត

ប៉ុន្តែ គាត់ឈប់នៅឯក្រុងមីលេត ប្រហែល៣២គីឡូម៉ែត្រខាងត្បូងអេភេសូរ ហើយជូនដំណើរពួកចាស់ទុំនៃពួកជំនុំនៅក្នុងអេភេសូរ (ខ.១៧)។ ការនេះជួយអោយយើងយល់ពាក្យសំដីសាវកប៉ុលនៅទីនេះបានត្រឹមត្រូវ។ គាត់កំពុងតែប្រញាប់ទៅឯយេរូសាឡិមនៅថ្ងៃបុណ្យទី៥០។ គាត់នៅក្នុងទូកធ្វើដំណើរនៅឯសមុទ្រ។ គាត់ហាក់ដូចជាមានការទទួលខុសត្រូវលើការនាំផ្លូវធ្វើដំណើរ (២០:១៦ គាត់គឺជាអ្នក សំរេចចិត្តធ្វើដំណើរតាមសមុទ្រកាត់តាមអេភេសូរ) ហើយគាត់បញ្ជាអោយនាយនាវាបើកបរនាវាទៅកំពង់ផែក្រុងមីលេត ដើម្បីបញ្ជូនអ្នកនាំសារម្នាក់ត្រឡប់ទៅអេភេសូរវិញ ដែលមានចម្ងាយជាង៣២គីឡូម៉ែត្រ ហើយរង់ចាំពួកចាស់ទុំពួកជំនុំ ដើម្បីអោយគាត់អាចនិយាយទៅកាន់ពួកគេនូវអ្វី ដែលយើងអាននៅក្នុងកិច្ចការ ២០:១៧-៣៥។

សេចក្តីពិតដែលថា សាវកប៉ុលនឹងប្រឈមនឹងទុក្ខលំបាកយ៉ាងខ្លាំងនេះ ដើម្បីផ្តល់សារនេះដល់ពួកចាស់ទុំពួកជំនុំដោយផ្ទាល់ ហើយសេចក្តីពិតដែលថា លោកលូកានឹងផ្អាកក្នុងរឿងរបស់គាត់ រួចកត់ត្រាពាក្យសំដីសំរាប់យើង ធ្វើអោយពាក្យសំដីទាំងនោះមានភាពអស្ចារ្យយ៉ាងខ្លាំងដល់ខ្ញុំ។ ពាក្យសំដីបានប៉ះពាល់ចិត្តខ្ញុំយ៉ាងខ្លាំង។ ពាក្យសំដីទាំងនោះបង្ហាញយើងយ៉ាងច្រើនអំពីទឹកចិត្តរបស់សាវកប៉ុល ក៏ដូចជាទេវសាស្ត្ររបស់គាត់ និងទស្សនៈរបស់គាត់អំពីភាពជាអ្នកដឹកនាំផងដែរ។ ការបញ្ចប់សារនេះធ្វើអាយគេមានចិត្តតានតឹង នៅពេលគាត់យំជាមួយមិត្តភ័ក្តិទាំងនោះ ហើយថើបពួកគេ ពីព្រោះគាត់នឹងមិនឃើញពួកគេម្តងទៀតទេរហូតបានទៅដល់ស្ថានសួគ៌។

## ហេតុអ្វីពាក្យសំដីទាំងនេះសំខាន់ខ្លាំងម្លេះ?

ចំលើយមួយគឺ អនាគតរបស់ពួកជំនុំអេភេសូរពឹងផ្អែកលើរបៀប ដែលពួកចាស់ទុំរបស់ពួកជំនុំបំរើព្រះអម្ចាស់ ហើយនៅទីនេះលោកប៉ុលនិយាយអំពីការបម្រើរបស់ចាស់ទុំ។ ដូច្នេះ មុនពេលសាវកប៉ុលផ្តល់ការណែនាំ ឬការព្រមានអ្វីមួយនៅក្នុងខ.២៨-៣១ គាត់រំលឹកពួកគេអំពីរបៀប ដែលគាត់បានបំរើព្រះអម្ចាស់នៅក្នុងរយៈពេលបីឆ្នាំជាមួយគ្នា។ នេះគឺជាអ្វី ដែលយើងនឹងសំឡឹងមើលនៅថ្ងៃនេះ។

មានភាពច្បាស់លាស់ចាប់ពីខ.៣៥ថា បំណងសាវកប៉ុលក្នុងការរំលឹកពួកគេអំពីការបម្រើរបស់គាត់ផ្ទាល់គឺដើម្បីបង្រៀនពួកគេអំពីការបម្រើ «ខ្ញុំបានបង្ហាញអ្នករាល់គ្នាដោយគ្រប់ការទាំងអស់ថា គួរ

អោយខំធ្វើការដូច្នោះ ដើម្បីបានជួយដល់ពួកអ្នកខ្សោយ...» សូមកត់សំគាល់៖ «ខ្ញុំបានបង្ហាញអ្នករាល់គ្នា!» ជីវិតរបស់ខ្ញុំ (លោកប៉ុល)គឺជាមេរៀនអំពីរបៀបដឹកនាំហ្វូងចៀមរបស់ព្រះ។

ដូច្នេះ នៅក្នុង ខ.១៨-២១ លោកប៉ុលបង្រៀនអំពីរបៀបចាស់ទុំត្រូវបំរើព្រះអម្ចាស់សំរាប់ផលប្រយោជន៍របស់ពួកជំនុំ។ នេះគឺជាអ្វី ដែលអ្នកជាចាស់ទុំត្រូវធ្វើ។ ពួកចាស់ទុំពួកជំនុំត្រូវមានលក្ខណៈដូច្នេះ ហើយជាអ្វី ដែលមនុស្សនៅក្នុងពួកជំនុំរបស់យើងត្រូវអធិស្ឋានសំរាប់ពួកអ្នកដឹកនាំរបស់ពួកគេ។ នោះឯងគឺជាអ្វី ដែលអ្នករាល់គ្នាត្រូវគ្រាប់តាម ពីព្រោះវាទាក់ទងនឹងអ្នករាល់គ្នា (ហេព្រើរ ១៣:១៧)។

ដូច្នេះចូរមើលលើអ្វី ដែលសាវកប៉ុលនិយាយអំពីព័ន្ធកិច្ចគាត់។ សូមចងចាំថា គាត់ត្រូវតែនិយាយដោយស្មោះត្រង់ (អំពីអ្វីដែលគាត់ធ្វើ) ពីព្រោះពួកចាស់ទុំទាំងនេះគឺជាមនុស្ស ដែលបានមើលគាត់អស់រយៈពេលបីឆ្នាំ។ នេះគឺជាអ្វី ដែលអ្នកគួរតែស្វែងរក៖ តើអ្វីជាសញ្ញានៃចាស់ទុំពួកជំនុំល្អម្នាក់? តើអ្នកដឹកនាំប្រភេទណា ដែលពួកជំនុំត្រូវការ? តាមព្រះគម្ពីរ តើ «បំរើព្រះអម្ចាស់» មានន័យយ៉ាងដូចម្តេច ?

## ការបម្រើព្រះជាម្ចាស់

ខ.១៨-១៩ «ឯកិរិយារបស់ខ្ញុំ គ្រប់ពេល គ្រប់វេលា ដែលនៅជាមួយនឹងអ្នករាល់គ្នា តាំងពីថ្ងៃ ដែលខ្ញុំចូលទៅស្រុកអាស៊ីមុនដំបូង គឺដែលខ្ញុំបានបំរើ ព្រះអម្ចាស់...»។

## អ្នកដឹកនាំជាអ្នកបំរើក្រោមការគ្រប់គ្រងព្រះអម្ចាស់

ការដំបូង ដែលសាវកប៉ុលចង់និយាយអំពីការងារគាត់គឺគាត់បាននិងកំពុងបំរើព្រះអម្ចាស់។ ការបំរើព្រះអម្ចាស់ហាក់ដូចជាគំនិតធម្មតាមួយ។ ប៉ុន្តែតើមានអ្វីលេចឡើងនៅក្នុងគំនិតរបស់អ្នកនៅពេលអ្នកគិតអំពី «ការបំរើ»? ចិត្តសុភាព ភាពចុះចូល និងការស្តាប់បង្គាប់តាម។

ឥឡូវនេះ នៅពេលអ្នកនិយាយថា «ព្រះអម្ចាស់» តើអ្នកគិតអំពីអ្វី? មិនមែន «លោកម្ចាស់ម្នាក់» ឬ «លោកម្ចាស់របស់ខ្ញុំ» ទេ ប៉ុន្តែ «ព្រះអម្ចាស់!»។ យើងគិតអំពី អំណាច ឫទ្ធានុភាព ព្រះចេស្តា ទ្រង់ជាអ្នកគ្រប់គ្រងឥទ្ធានុភាព។

ឥឡូវនេះ នៅពេលអ្នកដាក់ពាក្យទាំងនេះបញ្ចូលគ្នា នឹងបង្កើតអោយមានប្រភេទភាពជាអ្នកដឹកនាំមិនធម្មតាមួយ។ លក្ខណៈមួយចំនួននៃភាពជាអ្នកដឹកនាំនេះចេញមកពីសេចក្តីពិតដែលថា ជាដំបូងអ្នកដឹកនាំគឺជាអ្នកបំរើម្នាក់។ ហើយលក្ខណៈមួយចំនួនចេញមកពីសេចក្តីពិតដែលថា គាត់បំរើ «ព្រះអម្ចាស់» ហើយនៅពេលព្រះអម្ចាស់មានបន្ទូលប្រាប់គាត់អោយនិយាយអ្វី ឬធ្វើអ្វី នោះគាត់និយាយនិងធ្វើយ៉ាងនោះដោយមានទំនុកចិត្តនិងអំណាចដ៏អស្ចារ្យ។ ឥឡូវនេះ តើអ្នកអាចដាក់សេចក្តីពិតទាំងពីរនេះជាមួយគ្នាដែរឬទេ? តើអ្នកអាចមើលឃើញលក្ខណៈ ដែលគួរតែមាននៅក្នុងពួកចាស់ទុំពួកជំនុំដែរឬទេ?

## តើលោកប៉ុលបង្រៀនអ្វីអំពីការបម្រើរបស់ចាស់ទុំ?

បើសិនគ្មានជំនួយពីព្រះគម្ពីរ នោះខ្ញុំពិតជាមិនទុកចិត្តថា ខ្ញុំមានសមត្ថភាពឆ្លើយសំនួរនោះបានទេ។ នេះគឺជាមូលហេតុ ដែលខ្ញុំមានទំនុកចិត្តតិចតួចមែនទែនលើមនុស្ស ដែលអះអាងថា ខ្លួនកំពុងនិយាយតាមព្រះគម្ពីរ នៅពេលពួកគេរើសយកផ្ទៃរឿងក្នុងព្រះគម្ពីរ (ដូចជា «យុត្តិធម៌» ឬ «សន្តិភាព» ឬ «ភាពជាអ្នកបំរើ» ឬ «ភាពស្មើភាពគ្នា») ហើយពួកគេបិទព្រះគម្ពីរ និងចាប់ផ្តើមនិយាយអំពីផ្ទៃរឿងតាមអ្វី ដែលពួកគេចង់និយាយ ហើយពួកគេគិតថា មានអំណាចរបស់ព្រះគម្ពីរគាំទ្រអ្វីដែលគេបង្រៀន។

អ្វីទាំងអស់ ដែលមានបន្ទាប់ពីខ.១៨ដល់២១ គឺជាប្រយោគមួយនៅក្នុងភាសាដើម។ វាគឺជារបៀប ដែលសាវកប៉ុលបានពន្យល់អំពីរបៀប ដែលគាត់បានបំរើព្រះអម្ចាស់។ ការពិត នៅទីនេះយ៉ាងហោចណាស់មានលើកឡើងអំពីលក្ខណៈនៃការបំរើព្រះអម្ចាស់ចំនួនដប់បី។ វាមិនល្អទេបើសិនយើងគ្រាន់តែនិយាយថា «ពួកចាស់ទុំគួរតែបំរើព្រះអម្ចាស់» បន្ទាប់មកបិទព្រះគម្ពីររបស់យើង ហើយប្រឹក្សាគ្នាអំពីរបៀបយើងអនុវត្តតាមសេចក្តីពិតនេះនៅក្នុងជីវិតរបស់យើង។

## លក្ខណៈនៃការបំរើព្រះអម្ចាស់

### ១. ចិត្តសុភាព

ខ.១៩ក៖ ការបំរើព្រះអម្ចាស់មានន័យថា ចិត្តសុភាព។ «បំរើព្រះអម្ចាស់ ដោយចិត្តសុភាពគ្រប់ជំពូក [ការបន្ទាបខ្លួន]។»

<u>សេចក្តីទីមួយ</u> ដែលសាវកប៉ុលត្រូវនិយាយនោះគឺថា ការធ្វើជាអ្នកបំរើរបស់ព្រះអម្ចាស់មានន័យថា ការបន្ទាបខ្លួន និងសុភាព។ ចិត្តសុភាព ឬការបន្ទាបខ្លួនគឺជាអារម្មណ៍មួយចំពោះព្រះថា ទ្រង់មានសិទ្ធិពេញលេញលើជីវិតរបស់អ្នក ហើយថា ទ្រង់អាចប្រព្រឹត្តនឹងអ្នកតាមដែលទ្រង់សព្វព្រះទ័យ ហើយថា ទ្រង់មានអំណាចពេញលេញក្នុងការប្រាប់អ្នកអំពីអ្វី ដែលប្រសើរបំផុតសំរាប់អ្នក។ ចិត្តសុភាព ឬការបន្ទាបខ្លួនគឺជាចិត្តដែលប្រគល់ខ្លួន និងចុះចូលចំពោះព្រះអម្ចាស់ជាចៅហ្វាយរបស់ខ្លួន។ យើងជាដីឥដ្ឋនៅក្នុងដៃរបស់ជាងស្មូន។

<u>ទីពីរ</u> ចិត្តសុភាពមានន័យថា យើងមានអាកប្បកិរិយាជំពាក់គុណចំពោះមនុស្សទាំងអស់ ដោយសារ ព្រះគុណដែលព្រះអង្គបានប្រទានអោយយើង។ អាកប្បកិរិយានេះផ្ទុយនឹងអាកប្បកិរិយាដែលថា គ្រប់គ្នាជំពាក់ខ្ញុំ។ ការពិត ប្រហែលជាឥឡូវនេះមានមនុស្សម្នាក់ ដែលជំពាក់អ្វីមួយដល់អ្នក។ ប៉ុន្តែកាលណាអ្នកគិតតែអំពីអ្វី ដែលអ្នកដទៃជំពាក់អ្នក ជាជងអំពីអ្វី ដែលអ្នកជំពាក់ពួកគេនៅក្នុងសេចក្តីស្រឡាញ់និងការបំរើ នោះអ្នកកាន់តែមានចិត្តសុភាពបន្តិចបន្តួចទៅៗ។

ចិត្តសុភាពនិយាយថា ខ្ញុំជាកូនបំណុលរបស់អ្នកប្រាជ្ញ អ្នកល្ងង់ មិត្តភ័ក្តិ និងសត្រូវ។ នៅពេលយើងបន្ទាបខ្លួន នោះយើងមិនគិតអំពីសិទ្ធិរបស់យើងទេ។ យើងធ្វើអោយខ្លួនយើងនៅទទេ រួចយកទម្រង់ជាអ្នក បំរើម្នាក់ ហើយស្តាប់បង្គាប់ដល់ទីមរណៈ។

ដូច្នេះ សេចក្តីទីមួយ ក្នុងការបំរើព្រះអម្ចាស់មានន័យគឺ ចិត្តសុភាព។

**២. ដោយស្រក់ទឹកភ្នែក**

ខ.១៩ «ខ្ញុំបានបំរើ ព្រះអម្ចាស់ ដោយចិត្តសុភាពគ្រប់ជំពូក ហើយស្រក់ទឹកភ្នែកជាច្រើន»។

ទឹកភ្នែក អាចមកពីការឈឺចាប់ខាងរាងកាយ ឬឈឺចិត្ត ឬពីការខកចិត្ត និងការធ្លាក់ទឹកចិត្ត ឬពីក្តីប្រាថ្នាដ៏ខ្លាំងក្លាមួយ ឬពីក្តីអំណរដ៏លើសលប់។ ខ្ញុំមិនដឹងថា សាវកប៉ុលចង់សំដៅមួយណានៅទីនេះទេ។ នៅក្នុងខ.៣១ គាត់និយាយថា «ខ្ញុំចេះតែប្រដៅអ្នករាល់គ្នា ដោយទឹកភ្នែក ទាំងយប់ទាំងថ្ងៃ»។ ដូច្នេះ នៅក្នុងករណីនោះ ទឹកភ្នែករបស់គាត់គឺជាទឹកភ្នែកនៃក្តីប្រាថ្នាយ៉ាងខ្លាំងសំរាប់សេចក្តីជំនឿនិងភាពបរិសុទ្ធ របស់ពួកគេ។

ប៉ុន្តែនៅក្នុងខ.១៩ គាត់មិននិយាយអំពីមូលហេតុ ដែលគាត់បានយំជាញឹកញាប់ឡើយ។ ដូច្នេះ តើយើងគួរតែរៀនបានអ្វី? បើសិនទឹកភ្នែកទាំងនេះគឺជាភាពកម្សោយខាងអារម្មណ៍របស់សាវកប៉ុល នោះពួកមិនសូវមានអត្ថន័យប៉ុន្មានទេ។ គាត់មិនគួរនិយាយអំពីទឹកភ្នែករបស់គាត់ទេ។ ទេ ខ្ញុំគិតថា អ្វីដែលយើងគួរតែរៀនបានគឺថា ការបំរើព្រះអម្ចាស់មានន័យថា ការទាក់ទងយ៉ាងខ្លាំងជាមួយទុក្ខលំបាករបស់មនុស្ស ដែលអ្នកយំសំរាប់ពួកគេ។

រវាងពេលវេលា ដែលខ្ញុំបានចាកចេញពីផ្ទះឪពុកម្តាយ ពេលខ្ញុំនៅជាក្មេងជំទង់ក្នុងឆ្នាំ១៩៤៦និងពេលវេលាដែលខ្ញុំបានក្លាយជាចាស់ទុំ ដែលបង្រៀន ជាគ្រូគង្វាលនៃពួកជំនុំនេះក្នុងឆ្នាំ១៩៨០ ខ្ញុំគិតថា ខ្ញុំអាចបានរាប់នៅក្នុងដៃមួយនូវចំនួនពេលវេលា ដែលខ្ញុំបានយំ (នៅក្នុងរយៈពេល១៦ឆ្នាំ!)។ ប៉ុន្តែចាប់តាំងពីខ្ញុំបានក្លាយជាអ្នកគង្វាលម្នាក់នៃហ្វូងចៀមនេះ ខ្ញុំយំច្រើនជាងមុន។

ដូច្នេះ អត្ថបទនេះផ្តល់អោយខ្ញុំនូវសេចក្តីកំសាន្តចិត្តដ៏ធំមួយ។ នៅក្នុងខ.៣១ គាត់និយាយថា គាត់បានប្រដៅដោយទឹកភ្នែកទាំងយប់ទាំងថ្ងៃ! ប្រហែលជាថ្ងៃណាមួយខ្ញុំនឹងធ្វើដូច្នេះដែរ។

ដូច្នេះ សញ្ញាទីពីរនៃការបំរើគឺ៖ ការបំរើព្រះអម្ចាស់ក្នុងនាមជាចាស់ទុំម្នាក់នៅក្នុងពួកជំនុំរបស់ព្រះនឹងមានន័យថា ស្រក់ទឹកភ្នែក ពីព្រោះវានឹងមានន័យថា ការពាក់ព័ន្ធនៅក្នុងការតស៊ូរបស់មនុស្សសំរាប់ជំនឿ សេចក្តីសង្ឃឹម សេចក្តីពិត និងភាពបរិសុទ្ធ។

## ៣. សេចក្ដីល្បង

ខ.១៩ «ខ្ញុំបានបំរើ ព្រះអម្ចាស់ ដោយចិត្តសុភាពគ្រប់ជំពូក ហើយស្រក់ទឹក ភ្នែកជាច្រើនទាំងត្រូវសេចក្ដី ល្បង (លំបាក) ដោយកិច្ចកលរបស់ ពួកសាសន៍យូដា»។

ហេតុអ្វីពេលនេះសាវកប៉ុលរំលឹកពួកចាស់ទុំអំពីសេចក្ដីល្បង(លំបាក)ទាំងនេះ ដែលគាត់បានឆ្លងកាត់? ចំលើយគឺថា ពួកគេនឹងឆ្លងកាត់សេចក្ដីល្បង (លំបាក)ដែរ។ ចូរពិចារណាអំពីចំណុចនេះ៖ នៅក្នុង ១កូរិនថូស ១៥:៣២ សាវកប៉ុលបាននិយាយថា «បើសិនខ្ញុំបានតយុទ្ធនឹងសត្វព្រៃនៅក្រុងអេភេសូរ តាមរបៀបជាមនុស្ស។» តើគាត់បានចង់មានន័យយ៉ាងដូចម្ដេច? សូមប្រៀបធៀបជាមួយកិច្ចការ ២០:២៩ នៅពេលគាត់បាននិយាយថា «ដ្បិតខ្ញុំដឹងថា ក្រោយដែលខ្ញុំទៅបាត់ នោះនឹងមានឆ្កែព្រៃដ៏សាហាវ ដែលមិនចេះប្រណីដល់ហ្វូង វានឹងចូលមកក្នុងពួកអ្នករាល់គ្នា ហើយក្នុងចំណោមអ្នករាល់គ្នា ក៏នឹងកើតមានមនុស្ស ដែលអធិប្បាយសេចក្ដីទំនាស់ខុសដែរ ដើម្បីនឹងទាញនាំពួកសិស្សទៅតាមគេវិញ ដូច្នេះ អោយចាំយាមចុះ...»។

សាវកប៉ុលបាននិយាយថា គាត់បានតយុទ្ធជាមួយសត្វព្រៃនៅក្រុងអេភេសូរ ហើយគាត់និយាយថា ពួកចាស់ទុំនៅក្នុងក្រុងអេភេសូរនឹងត្រូវតយុទ្ធជាមួយឆ្កែព្រៃដ៏សាហាវ។ មានគំនិតតែមួយនៅក្នុងករណីទាំងពីរនេះ ហើយជាគំនិតដូចគ្នា ដែលព្រះយេស៊ូវ បង្រៀន នៅពេលទ្រង់បានមានបន្ទូលថា «នែ ខ្ញុំចាត់អ្នករាល់គ្នាអោយទៅ ដូចជាចៀមនៅកណ្ដាលហ្វូងស្វាន» (ម៉ាថាយ ១០:១៦)។ មានមនុស្ស ដែលនៅពេលពួកគេស្ដាប់លឺការអះអាង របស់ព្រះយេស៊ូវគ្រីស្ទ គេត្រឡប់ជាខឹងសម្បារដូចជាសត្វ។

ហើយអ្វីគួរអោយសោកស្ដាយគឺថា នៅក្នុងកិច្ចការ ២០:២៩ សាវកប៉ុលនិយាយថា ឆ្កែព្រៃទាំងនេះនឹងចេញមកពីចំណោមចំនួនរបស់ពួកគេផ្ទាល់! និយាយតាមពាក្យផ្សេងគឺថា ពួកចាស់ទុំមួយចំនួននៅក្នុងពួកជំនុំក្រុងអេភេសូរនឹងត្រឡប់ជាខ្មាំងសត្រូវជាមួយសេចក្ដីពិត និងសេចក្ដីសុចរិត។ ពួកគេនឹងអធិប្បាយសេចក្ដីទំនាស់ខុសអំពីព្រះរាជសារ និងជីវិតរបស់ពួកចាស់ទុំដទៃទៀត។ ពួកគេអាចបង្កើតគម្រោងការក្បត់នឹងគ្នាឯង ដូចជាញាតិសន្ដានរបស់សាវកប៉ុលបានបង្កើតគម្រោងការក្បត់ចំពោះគាត់ផងដែរ (២០:៣; ១៩:៩)។ ហើយសាវកប៉ុលនិយាយថា នេះគឺជាសេចក្ដីល្បង(លំបាក) ដ៏ធំមួយ។

ដូច្នេះ យើងបានមើលឃើញថា ការបំរើព្រះអម្ចាស់មានន័យ សំដៅលើ កិច្ចការបីយ៉ាង។ វាមានន័យថា ដោយចិត្តសុភាព ដោយស្រក់ទឹកភ្នែក និងសេចក្ដីល្បង (លំបាក) ។ ហើយខ្ញុំចង់ហៅអ្នកអោយបំរើព្រះអម្ចាស់នៅក្នុងរបៀបទាំងនេះ។

- ដោយចិត្តសុភាព៖ ចូរចុះចូលចំពោះព្រះអម្ចាស់ទាំងស្រុង។ ចូរចុះចូលចំពោះសិទ្ធិដាច់ខាតរបស់ទ្រង់ក្នុងការគ្រប់គ្រងជីវិតរបស់អ្នក។ ចូរមានចិត្តធ្វើជាជីតដ្ឋនៅក្នុងដៃរបស់ជាងស្មូន។ ហើយចូរធ្វើ

ជាអ្នកជំពាក់ដល់មនុស្សទាំងអស់។ កុំគិតតែពីអ្វី ដែលគេជំពាក់អ្នក។ ចូរគិតអំពីព្រះគុណរបស់ព្រះ ដែលធ្វើអោយអ្នកជាអ្នកជំពាក់ដល់មនុស្សទាំងអស់។

- ដោយទឹកភ្នែក៖ បើសិនអ្នកកំពុងស្រក់ទឹកភ្នែក ចូរអោយមានការកំសាន្តចិត្តចុះ ពីព្រោះសាវកប៉ុល បានស្រក់ទឹកភ្នែកផងដែរ។ បើសិនអ្នកមិនស្រក់ទឹកភ្នែកទេ នោះប្រហែលអ្នកអធិស្ឋានអោយព្រះជួយអ្នកអោយមើលឃើញអំពីសារៈសំខាន់នៃការតយុទ្ធសំរាប់ជំនឿនិងសេចក្តីសង្ឃឹម និងសេចក្តីបរិសុទ្ធ។
- សេចក្តីល្បង (លំបាក)៖ បើសិនអ្នកមានសេចក្តីល្បង (លំបាក) នោះចូរស្តាប់ពាក្យរបស់សាវកយ៉ាកុបថា «បងប្អូនអើយ កាលណាអ្នករាល់គ្នាមានសេចក្តីល្បងផ្សេងៗ នោះ ត្រូវរាប់ជាសេចក្តីអំណរសព្វគ្រប់វិញ ដោយដឹងថា ការល្បងលមើលសេចក្តីជំនឿនៃអ្នករាល់គ្នា នោះនាំ បង្កើតអោយមានសេចក្តីខ្ជាប់ខ្ជួន ចូរទុកអោយសេចក្តីខ្ជាប់ខ្ជួននោះ បានធ្វើការអោយសំរេចពេញលេញចុះ ដើម្បីអោយអ្នករាល់គ្នាបានគ្រប់លក្ខណ៍ ហើយពេញខ្នាតឥតខ្វះអ្វីឡើយ» (យ៉ាកុប ១:២-៤)។

## ៤. ភាពក្លាហាន

ខ.២០៖ ការបំរើព្រះអម្ចាស់មានន័យថា ភាពក្លាហាន។ «ខ្ញុំមិនបានខាននឹង...»។

សូមមើលកិច្ចការ ២០:២៧ (មិនបានខាននឹងប្រាប់អ្នករាល់គ្នា ពីគ្រប់ទាំងគំនិតរបស់ព្រះទេ) កាឡាទី ២:១២ (ពេត្រុសដកខ្លួនថយមិនបរិភោគជាមួយពួកសាសន៍ដទៃ ដោយកោតខ្លាច) ហេព្រើរ ១០:៣៨..(ថយពីជីវិតតស៊ូសំរាប់ជំនឿនិងការស្តាប់បង្គាប់)។

ចាស់ទុំល្អមិនសំរេចចិត្តបង្រៀនអ្វី ដែលមានប្រជាប្រិយភាព ឬមនុស្សងាយស្រួលទទួលយកនោះទេ។ បើសិនមានផ្នែកនៃព្រះបន្ទូលដែលមនុស្សគិតថាពិបាកទទួល នោះចាស់ទុំគួរតែបង្រៀនព្រះបន្ទូល ពីព្រោះវាមានប្រយោជន៍។ ចាស់ទុំដ៏ស្មោះត្រង់មិនបានខាននឹងប្រាប់ព្រះបន្ទូលនោះទេ។  ការនេះត្រូវការភាពក្លាហាន។

វាក៏ត្រូវការ  ការសិក្សា និងគំនិតផងដែរ។ សូមមើលទីតុស ១:៩ ដែលពួកចាស់ទុំត្រូវ «ព្រមទាំងកាន់ខ្ជាប់តាមព្រះបន្ទូលដ៏ពិត ដូចជាបានបង្រៀនមកយើងហើយ ដើម្បី [អ្នក] ឲ្យអាចនឹងកំសាន្តចិត្តគេ ដោយសេចក្តីបង្រៀនដ៏ត្រឹមត្រូវ ហើយឲ្យបានផ្ចាញ់ដល់ពួកអ្នកដែលស្រដីទទឹង។» បើសិនអ្វីមួយ ដែលអាចអោយជំទាស់គ្នាបាន នោះពួកចាស់ទុំត្រូវតែ សិក្សា ហើយមានសមត្ថភាពផ្តល់ចំលើយសមហេតុផលដែលយោងតាមព្រះគម្ពីរ ។

## ៥. ការប្រាប់សេចក្ដី (ការប្រកាស)

ខ.២០៖ ពេលខ្លះការបំរើព្រះអម្ចាស់មានន័យថា ការប្រាប់សេចក្ដី។ «ខ្ញុំមិនបានខាននឹងប្រាប់សេចក្ដី...ដល់អ្នករាល់គ្នា»។

ការប្រាប់សេចក្ដីមានន័យខុសពី «បង្រៀន» ។ ការប្រាប់សេចក្ដីមិនសង្កត់ធ្ងន់ទៅលើការពន្យល់អំពីអត្ថន័យនៃអត្ថបទគម្ពីរទេ តែមានការសង្កត់ធ្ងន់លើការនាំដំណឹង ឬការប្រកាសអ្វីមួយសំខាន់ ឬការនាំដំណឹងអំពីព្រឹត្តិការណ៍នឹងមកដល់ ឬការប្រកាសអំពីជ័យជំនះ។

មានភាពខុសគ្នាមួយរវាងការពន្យល់អំពីរបៀបលេងបាល់ទាត់និងការនាំដំណឹងថា ប្រទេសអាឡឺម៉ង់ឈ្នះប្រទេសប្រេស៊ីល។ មានភាពខុសគ្នាមួយរវាងអ្វី ដែលអ្នកប្រកាសធ្វើក្នុងកំឡុងពេលប្រកួត និងអ្វី ដែលកើតឡើងនៅពាក់កណ្ដាលទី នៅពេលអ្នកវិភាគពន្យល់ដោយមានដ្យាក្រាម។

យើងត្រូវការទាំងការប្រាប់សេចក្ដី និងការបង្រៀន ពីព្រោះសេចក្ដីពិតរបស់គ្រីស្ទបរិស័ទមិនគ្រាន់តែជាចំណេះដឹង ដែលយើងត្រូវវិភាគ និងយល់ប៉ុណ្ណោះ ប៉ុន្តែលើសពីនេះទៅទៀត យើងគួរតែគាប់ចិត្តនឹងសេចក្ដីពិតរបស់គ្រីស្ទបរិស័ទ។ យើងត្រូវការស្ដាប់លឺការប្រកាសអំពីសេចក្ដីពិតរបស់ព្រះគម្ពីរ ដែលនាំអោយយើងមានអារម្មណ៍សប្បាយរីករាយនឹងសេចក្ដីពិតនោះ។ យោងតាមការយល់របស់ខ្ញុំអំពីពាក្យទាំងពីរ នេះគឺជាភាពខុសគ្នារវាងការប្រកាស និងការបង្រៀន។

មិនមែនពួកចាស់ទុំទាំងអស់ត្រូវការធ្វើជាអ្នកប្រាប់សេចក្ដីល្អ ឬអ្នកអធិប្បាយល្អនោះទេ។ ប៉ុន្តែទាំងអស់គ្នាគួរតែមានទឹកចិត្តប្រកាសអំពីដំណឹងល្អនៅពេលមានឱកាសល្អ ហើយគួរតែសប្បាយចិត្តនៅពេលមនុស្សប្រកាសដំណឹងល្អ។

## ៦. ការរស់នៅសំរាប់អ្វី ដែលមានប្រយោជន៍ដល់ពួកជំនុំ

ខ.២០៖ ការបំរើព្រះអម្ចាស់មានន័យថា ការរស់នៅសំរាប់អ្វី ដែលជួយដល់ពួកជំនុំ។ «ខ្ញុំមិនបានខាននឹងប្រាប់សេចក្ដីអ្វី ដែលមានប្រយោជន៍ដល់អ្នករាល់គ្នា...»។

«ចាស់ទុំដែលប្រកាស» ល្អម្នាក់ មិនគ្រាន់តែអធិប្បាយអំពីអ្វីដែលគាត់មើលឃើញថាស្រួលប៉ុណ្ណោះទេ ប៉ុន្តែគាត់សួរថា តើអ្វីនឹងមានប្រយោជន៍ដល់ពួកជំនុំ? ហើយគាត់ត្រូវតែដឹងអំពីអ្វី ដែលមានប្រយោជន៍។ តើវាជាតំលៃខ្លួនឬ? តើវាជាប្រាក់កាសឬ? តើវាធ្វើអោយបញ្ញាចិត្តស្ងប់ស្ងាត់ឬ? ហោរាយេរេមា បាននិយាយទាស់ប្រឆាំងនឹងពួកហោរា និងពួកសង្ឃ ដែលថា «បានមើលរបួសរបស់រាស្ត្រអញ អោយសះតែបន្តិចបន្តួចទេ ដោយពោលតែពាក្យថា សុខៗប៉ុណ្ណោះ ក្នុងកាលដែលឥតមានសេចក្ដីសុខឡើយ» (៦:១៤; ៨:១១)។

គោលដៅរបស់យើងគឺត្រូវផ្តល់សេចក្តីបង្រៀន ដែលមានប្រយោជន៍អស់កល្បជានិច្ច មិនមែនជាសេចក្តីខុស និងការកំសាន្តបណ្តោះអាសន្នឡើយ។ ពួកចាស់ទុំស្មោះត្រង់គួរតែបន្តសួរសំនួរនេះថា «តើអ្វីនឹងធ្វើអោយមនុស្សបានល្អអស់កល្បជានិច្ច?»

## ៧. សមត្ថភាពបង្រៀន

ខ.២០៖ ការបំរើព្រះអម្ចាស់មានន័យថា ការបង្រៀន។ «ខ្ញុំមិនបានខាននឹងប្រាប់សេចក្តីអ្វី ដែលមានប្រយោជន៍ដល់អ្នករាល់គ្នាដែរ គឺបានបង្រៀនដល់អ្នករាល់គ្នា...»។

នៅក្នុងបញ្ជីលក្ខណៈសម្បត្តិសំរាប់ពួកចាស់ទុំនៅក្នុង១ធីម៉ូថេ ៣:២ និយាយថា គាត់គួរតែ «ចេះបង្រៀន»។ គាត់គួរតែមានអំណោយខាងការបង្រៀន។ មូលហេតុគាត់ត្រូវមានអំណោយនេះគឺថា ពួកចាស់ទុំទទួលខុសត្រូវចំពោះការការពារគោលលទ្ធិរបស់ហ្វូងចៀម ថែរក្សា ការពារ និងស្អាងគោលលទ្ធិពិតប្រាកដនៅក្នុងមនុស្ស។ នៅក្នុងទីតុស ១:៩ និយាយថា ពួកចាស់ទុំត្រូវតែ «ជាប់ចិត្តនឹងព្រះបន្ទូលជាគ្រឹះនៃជំនឿ ស្របតាមសេចក្តីដែលគេបានរៀន ដើម្បីអោយមានសមត្ថភាពដាស់តឿនអ្នកដទៃតាមសេចក្តីបង្រៀនដ៏ត្រឹមត្រូវ ព្រមទាំងចេះរកខុសត្រូវតបតនឹងពួកអ្នកប្រឆាំងផង»។

ការបង្រៀនខុសពី «ការប្រកាស» ពីព្រោះការបង្រៀនពន្យល់ផ្នែកនៃព្រះគម្ពីរ។ ការបង្រៀនផ្តោតលើការធ្វើអោយអត្ថន័យនៃអត្ថបទមានភាពច្បាស់លាស់។ នេហេមា ៨:៨ ថា «ពួកអ្នកទាំងនោះបានអានមើល ក្នុងគម្ពីរក្រឹត្យវិន័យរបស់ព្រះ ព្រមទាំងស្រាយន័យសេចក្តីឲ្យគេបានយល់បទដែលអានមើលនោះ។»

ការបង្រៀនល្អនិងការប្រកាសល្អជាទូទៅនឹងមានគ្នាទៅវិញទៅមកខ្លះ។

ការបង្រៀនដ៏ល្អនៅក្នុងពួកជំនុំនឹងនាំអោយមានពួកជំនុំរឹងមាំ។ ព្រះសព្វព្រះទ័យអោយមានពួកគ្រូបង្រៀនដែលជាគ្រូគង្វាលនៅក្នុងរូបកាយរបស់ព្រះគ្រីស្ទ (អេភេសូរ ៤:១១)។ លោកប៉ុលបានបង្រៀនពួកសិស្សហើយបានប្រកាសទៅកាន់ពួកអ្នកមកថ្មីអស់រយៈពេលពីរឆ្នាំ ឬយូរជាងនេះ។

## ៨. ព័ន្ធកិច្ចសាធារណៈមួយ

ខ.២០៖ ការបំរើព្រះអម្ចាស់មានន័យថា ព័ន្ធកិច្ចសាធារណៈមួយ។ «ខ្ញុំមិនបានខាននឹងប្រាប់សេចក្តី ដែលមានប្រយោជន៍ដល់អ្នករាល់គ្នាដែរ គឺបានបង្រៀនអ្នករាល់គ្នានៅកណ្តាលជំនុំវិញ (តាមទីសាធារណៈ)...»។

ដូច្នេះ សាវកប៉ុលសង្កត់ធ្ងន់ថា ការបម្រើរបស់គាត់ទៅកាន់ពួកសិស្សនិងពួកចាស់ទុំមិនមានភាពឯកជនសំងាត់អ្វីទាំងអស់។ ជាញឹកញាប់ ការបម្រើរបស់គាត់បើកចំហដល់គ្រប់មនុស្សទាំងអស់។ គ្រប់គ្នាអាចចូល

ទៅបានដោយសេរី ដែលប្រហែលចង់សំដៅទៅលើពេលគាត់បង្រៀននៅសាលាបង្រៀនរបស់ទីរ៉ានុស (កិច្ចការ ១៩:៩)។

គំនិតនោះអាចថា សេចក្តីពិតរបស់គ្រីស្ទបរិស័ទគឺជាសេចក្តីពិតជាសាធារណៈ គឺវាគ្មានអ្វីត្រូវខ្មាស ឬអ្វីត្រូវលាក់បាំងឡើយ។

ពួកចាស់ទុំទាំងអស់គួរតែបំពេញការបម្រើរបស់ខ្លួននៅក្នុងរបៀបនេះផងដែរ គឺគ្មានការបង្រៀនណាមួយដែលត្រូវគេរក្សាជាសំងាត់ឡើយ។

**៩.** ព័ន្ធកិច្ចផ្ទាល់ខ្លួន

ខ.២០៖ «ខ្ញុំមិនបានខាននឹងប្រាប់សេចក្តី ដែលមានប្រយោជន៍ដល់អ្នករាល់គ្នាដែរ គឺបានបង្រៀនអ្នករាល់គ្នានៅកណ្តាលជំនុំវិញ ពីផ្ទះ១ទៅផ្ទះ១ផង...»។

សាវកប៉ុលមិនស្កប់ចិត្ត ដែលតែងតែប្រកាសនិងបង្រៀនទៅកាន់មនុស្សមួយហ្វូងធំក្នុងទីសាធារណៈទេ។ គាត់ពិតជាបានបែងចែកពួកជំនុំជាក្រុមៗតាមផ្ទះ ហើយបានទៅឯក្រុមទាំងនោះ។ ឬវាអាចមានន័យថា គាត់បានទៅសួរសុខទុក្ខគ្រួសារ។

គាត់បានបង្រៀនព្រះបន្ទូលក្នុងរយៈពេលខ្លីៗពីផ្ទះ១ទៅផ្ទះ១ ដែលជាឱកាសកាត់អាចអនុវត្តព្រះបន្ទូលតាមកាលៈទេសៈនៃសមាជិកនានានៃពួកជំនុំ។

ចូរប្រៀបធៀបជាមួយកិច្ចការ ៥:៤២ ឃ្លាដូចគ្នា៖ ពួកសាវក «ចេះតែបង្រៀន ព្រមទាំងប្រាប់ដំណឹងល្អពីព្រះយេស៊ូវគ្រីស្ទ នៅក្នុងព្រះវិហារ ហើយនៅអស់ទាំងផ្ទះរាល់តែថ្ងៃជានិច្ច។»

ការនេះតម្រូវអោយពួកចាស់ទុំមិនគ្រាន់តែមានអំណោយទានធ្វើជាពួកគ្រូបង្រៀនប៉ុណ្ណោះ តែក៏មានអំណោយទានមានសមត្ថភាពពន្យល់និងអនុវត្តព្រះបន្ទូលព្រះដោយផ្ទាល់ខ្លួន។

**១០. កំឡាំងខាងវិញ្ញាណ បម្រើអស់ពីចិត្តដោយព្រះវិញ្ញាណបរិសុទ្ធជួយ**

ខ.២១៖ការបំរើព្រះអម្ចាស់មានន័យថា បម្រើអស់ពីចិត្ត។ «ខ្ញុំមិនបានខាននឹងប្រាប់សេចក្តី ដែលមានប្រយោជន៍ដល់អ្នករាល់គ្នាដែរ គឺបានបង្រៀនអ្នករាល់គ្នានៅកណ្តាលជំនុំ ហើយពីផ្ទះ១ទៅផ្ទះ១ផង (ខ.២១) ក៏ធ្វើបន្ទាល់...»។

ពាក្យភាសាក្រិក *diamarturomenos* ពេលខ្លះមានន័យថា ធ្វើសាក្សី (ធ្វើបន្ទាល់) នៅក្នុងន័យស្បថនៅក្នុងតុលាការ ហើយធ្វើសាក្សីអំពីអ្វី ដែលអ្នកដឹងអំពីហេតុការណ៍។ ប៉ុន្តែនៅទីនេះមានន័យថា ព្រមាន ឬប្រាប់យ៉ាងឧឡារិក ។ ដូច្នេះ ពាក្យដែលលោកប៉ុលប្រើនៅទីនេះនិងនៅក្នុងខ.២៤មានន័យថា គាត់បានប្រកាសអស់ពីចិត្តដល់មនុស្សដើម្បីដាស់តឿនគេនិងជំរុញគេអោយជឿនិងប្រែចិត្ត។

ភាពអស់ពីចិត្ត និងភាពប្រាកដប្រជា និងកំឡាំងខាងវិញ្ញាណមានភាពចាំបាច់បំផុតនៅក្នុងការដឹកនាំពួកជំនុំ។ វាគឺភាពផ្ទុយគ្នាទៅនឹងភាពធ្វេសប្រហែស។ ពួកចាស់ទុំត្រូវអនុវត្តភាពអស្ចារ្យនៃការងារអស់កល្បជានិច្ចដែលពួកគេកំពុងដោះស្រាយនៅក្នុងព្រះបន្ទូលរបស់ព្រះនិងសេចក្តីអធិស្ឋាននិងព្រលឹងរបស់មនុស្ស។

## ១១. ភាពមិនលំអៀង

ខ.២១៖ ការបំរើព្រះអម្ចាស់មានន័យថា បម្រើដោយមិនលំអៀង។ «ខ្ញុំមិនបានខាននឹងប្រាប់សេចក្តី ដែលមានប្រយោជន៍ដល់អ្នករាល់គ្នាដែរ គឺបានបង្រៀនអ្នករាល់គ្នានៅកណ្តាលជំនុំ ហើយពីផ្ទះ១ទៅផ្ទះ១ផង (ខ.២១) ក៏ធ្វើបន្ទាល់អស់ពីចិត្ត ដល់ទាំងពួកសាសន៍យូដា និងពួកសាសន៍ក្រេកផង...»។

ពួកចាស់ទុំមិនគួរមានភាពលំអៀងទៅលើមនុស្សក្រុមមួយជាងមនុស្សមួយក្រុមទៀតទេ ពីព្រោះគាត់នឹងមើលងាយមនុស្សក្រុមណាមួយមិនខាន។ ពួកជំនុំអាចចាត់តាំងចាស់ទុំម្នាក់អោយយកចិត្តទុកដាក់ពិសេសចំពោះយុវជន ឬពួកមនុស្សចាស់ ឬក្រុមគ្រួសារ ឬពួកមនុស្សនៅលីវបាន។ ទំនួលខុសត្រូវ ដែលមានការតែងតាំងដោយចំហនេះនឹងមិនមានភាពលំអៀងឡើយ។

ប៉ុន្តែចាស់ទុំម្នាក់ ដែលព្រងើយកន្តើយនិងមើលងាយក្រុមមួយនៅក្នុងពួកជំនុំ ដោយព្រោះគាត់មិនចូលចិត្តពួកគេគឺផ្ទុយនឹងគំរូរបស់សាវកប៉ុលនៅទីនេះហើយ។ ចាស់ទុំនានាគួរតែយកចិត្តទុកដាក់ចំពោះសុខុមាលភាពខាងវិញ្ញាណរបស់មនុស្សទាំងអស់នៅក្នុងពួកជំនុំ។

## ១២. ទទួចមនុស្សអោយប្រែចិត្តចំពោះព្រះ

ការបំរើព្រះអម្ចាស់មានន័យថា ទទួចមនុស្សអោយប្រែចិត្តចំពោះព្រះ។

សូមមើលចំនុច១៣។

## ១៣. ទទួចមនុស្សអោយជឿលើព្រះយេស៊ូវ

ខ.២១៖ ការបំរើព្រះអម្ចាស់មានន័យថា ទទួចមនុស្សអោយជឿលើព្រះយេស៊ូវ។ «ខ្ញុំមិនបានខាននឹងប្រាប់សេចក្តីអ្វី ដែលមានប្រយោជន៍ដល់អ្នករាល់គ្នាដែរ គឺបានបង្រៀនដល់អ្នករាល់គ្នានៅកណ្តាលជំនុំវិញ ហើយ

ពីផ្ទះ១ទៅផ្ទះ១ផង (ខ.២១) ក៏ធ្វើបន្ទាល់អស់ពីចិត្ត ដល់ទាំងពួកសាសន៍យូដា និងពួកសាសន៍ក្រេកផង គឺពីការប្រែចិត្តទៅឯព្រះ ហើយពីសេចក្ដីជំនឿជឿដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទនៃយើងរាល់គ្នា»។

ទីបំផុត យើងទទួលបានខ្លឹមសារនៃអ្វី ដែលសាវកប៉ុលបានប្រកាស និងបង្រៀន និងធ្វើបន្ទាល់ គឺការប្រែចិត្តមកឯព្រះ និងជំនឿនៅក្នុងព្រះយេស៊ូវ។

## មនុស្សចាំបាច់ត្រូវប្រែចិត្តនិងជឿ ដើម្បីទទួលសេចក្ដីសង្គ្រោះ

ទាំងពីរចាំបាច់សំរាប់សេចក្ដីសង្គ្រោះ

### ការប្រែចិត្ត

(កិច្ចការ ៣:១៩; ៥:៣១; ៨:២២; ១១:១៨; ១៧:៣០; ២៦:១៧-២០)

### សេចក្ដីជំនឿ

ចូរកត់សំគាល់អំពីស្ថានទៅកាន់ជំនឿពីការប្រែចិត្តនៅក្នុង ២៦:១៨!

(កិច្ចការ ១៤:២៧; (ប្រៀបធៀប ១១:១៨); ១៥:៩; ២៤:២៤-២៥)